**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារជូនពរ
## ផ្ញើជូន
## នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ
## ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ

***មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហាន គ្រប់ស្ថាប័ន កងឯកភាព នៃកងយោធពលខេមរភូមិន្ទ ជាទីស្នេហា!***

នាឱកាសដ៏វិសេសវិសាល ពោរពេញដោយក្តីសោមនស្សរីករាយ ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខាងមុខនេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នៃកងយោធពលខេមរភូមិន្ទ និងខ្លួនខ្ញុំផ្ទាល់ សូមសម្តែងនូវក្តីអំណរសាទរឥតឧបមា ជាមួយនូវសេចក្តីនឹករឭកយ៉ាងជ្រាលជ្រៅជាទីបំផុត និងសូមផ្តាំផ្ញើនូវការសាកសួរសុខទុក្ខដល់**មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់** ក្នុងកងយោធពលខេមរភូមិន្ទ ដែលកំពុងបំពេញភារកិច្ចនៅតាមបណ្តាស្ថាប័ន កងឯកភាពនានា សិក្ខាកាមដែលកំពុងតែសិក្សាទាំងក្នុង និងក្រៅប្រទេស ព្រមទាំងកងកម្លាំងបំពេញបេសកកម្មរក្សាសន្តិភាពក្រោមឆត្រអង្គការសហប្រជាជាតិ សូមទទួលបាននូវសុខភាពល្អបរិបូរ កម្លាំងមាំមួន និងសម្រេចបានជោគជ័យគ្រប់ភារកិច្ចជូនជាតិមាតុភូមិ។

ខ្ញុំសូមយកឱកាសដ៏មានអត្ថន័យនេះ សម្តែងនូវមោទនភាព និងវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលដ៏ធំធេងដែលកងយោធពលខេមរភូមិន្ទសម្រេចបានក្នុងពេលកន្លងមក គឺកើតចេញពីការលះបង់ ខិតខំពុះពារជម្នះគ្រប់ឧបសគ្គ និងការលំបាកនានា ប្រកបដោយភាពអង់អាចក្លាហាន មោះមុត ជាមួយនឹងការប្តេជ្ញាចិត្តខ្ពស់ ដើម្បីសម្រេចបាននូវជោគជ័យជូនជាតិមាតុភូមិ។ ក្រោមឯកសណ្ឋានដ៏មានកិត្តិយសឧត្តុង្គឧត្តមនេះ កងយោធពលខេមរភូមិន្ទ បានរួមចំណែកយ៉ាងសកម្មក្នុងការថែរក្សាសន្តិសុខជាតិ ការពង្រឹងបាននូវសន្តិសុខសណ្តាប់ធ្នាប់សង្គម ការពារសុវត្ថិភាពថ្នាក់ដឹកនាំ ស្ថិរភាពនយោបាយ ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី បានយ៉ាងគង់វង្សគ្រប់កាលៈទេសៈ ពង្រឹងខឿនការពារជាតិប្រជាជន រឹងមាំខ្លាំងក្លា ធ្វើឱ្យប្រជាពលរដ្ឋបានរស់នៅដោយសុខដុមរមនាលើទឹកដីរបស់ខ្លួន និងមានឱកាសពេញលេញសម្រាប់ការអភិវឌ្ឍសង្គមជាតិ។

ជាថ្មីម្តងទៀត **ក្នុងពិធីបុណ្យចូលឆ្នាំថ្មី** ប្រពៃណីជាតិ នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នៃកងយោធពលខេមរភូមិន្ទ និងខ្លួនខ្ញុំផ្ទាល់ សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតារក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមជួយប្រោះព្រំសព្វសាធុការពរជ័យ សិរីមង្គល ជូនចំពោះ**មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់** ក្នុងកងយោធពលខេមរភូមិន្ទ ព្រមទាំងនាយទាហានដែលកំពុងបំពេញបេសកកម្ម និងសិក្ខាកាមទាំងអស់ដែលកំពុងសិក្សាជំនាញនានាទាំងក្នុង និងក្រៅប្រទេស រួមទាំងយោធិនដែលមានជំងឺកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យ សូមឱ្យឆាប់ជាសះស្បើយពីជំងឺ មានកម្លាំងមាំមួនឡើងវិញ ដើម្បីបន្តបេសកកម្មដ៏ឧត្តុង្គឧត្តមជូនជាតិមាតុភូមិនៃយើង។

សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** ជានិច្ចនិរន្តរ៍តរៀងទៅ។

ថ្ងៃពុធ ១២កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ០២៣ ៨៨៣ ២៧៤ email: generalsec@mod.gov.kh